# រឿងទី៣៖ យ៉ូសែប២ (យ៉ូសែបនាយករដ្ឋមន្ត្រីនៃស្រុកអេស៊ីប)

**ខគម្ពីរ៖ លោកុប្បត្តិ៥០៖២០**

បងៗបានឃុបឃិតគ្នាធ្វើបាបខ្ញុំ តែព្រះជាម្ចាស់បានធ្វើឲ្យការនោះ ប្រែទៅជាល្អ ដូចយើងឃើញសព្វថ្ងៃនេះស្រាប់ គឺព្រះអង្គបានសង្គ្រោះជីវិតប្រជាជនមួយដ៏ធំ។

យ៉ូសែបបានក្លាយជានាយករដ្ឋមន្ត្រីស្រុកអេស៊ីបដែលមានឋានៈខ្ពស់បន្ទាប់ពីស្តេច។
ប្រាំពីរឆ្នាំដំបូង ក្រោយពីយ៉ូសែបបានក្លាយជានាយករដ្ឋមន្ត្រី ស្រុកទេសគឺស្ថិតនៅក្នុងភាពសម្បូរហូរហៀរ។
នៅក្នុងស្រុកអេស៊ីបគឺសម្បូរទៅដោយភោគផលជាច្រើន។
ពួកមន្ត្រីទាំងអស់នៅស្រុកអេស៊ីប បានធ្វើតាមការបង្គាប់របស់យ៉ូសែប ប្រមូលស្បៀងដាក់ពេញក្នុងឃ្លាំងនីមួយៗ។
ពេលឆ្នាំសម្បូរហូរហៀរត្រូវបានបញ្ចប់ ឆ្នាំនៃគ្រោះទុរ្ភិក្សក៏ចាប់ផ្តើមកើតមាន។
ភ្លៀងក៏លែងធ្លាក់ ធ្វើឱ្យស្រែចម្ការ និងដំណាំផ្សេងៗត្រូវស្ងិតក្រៀមដួលងាប់អស់ ប៉ុន្តែដោយព្រោះយ៉ូសែបមានប្រាជ្ញា គាត់បានប្រមូលស្បៀងទុកក្នុងឃ្លាំងជាច្រើន ក្នុងអំឡុងពេលឆ្នាំសម្បូរហូរហៀរ ដូច្នេះគាត់បានប្រាប់ប្រជាជនអេស៊ីប កុំឱ្យបារម្ភអ្វីឡើយ។
យ៉ូសែបបានយកស្បៀងដែលមាននៅក្នុងឃ្លាំងចែកដល់ប្រជាជន។
ដំណឹងថានៅអេស៊ីបមានស្បៀងយ៉ាងច្រើននោះ ក៏បានសាយភាយទៅទីឆ្ងាយៗ។
ដំណឹងនេះបានសាយភាយទៅដល់ទឹកដីកាណានដែលគ្រួសារយ៉ាកុបកំពុងអត់ឃ្លានដោយគ្រោះទុរ្ភិក្សនេះដែរ។
ថ្ងៃមួយ យ៉ាកុបបានហៅកូនប្រុសទាំងអស់មក រួចនិយាយថា៖ «ចូរពួកកូនចេញទៅអេស៊ីប ទៅទិញស្បៀងមក»។
បងប្រុសទាំងដប់នាក់របស់យ៉ូសែប បានចាកចេញទៅស្រុកអេស៊ីប ទុកតែបេនយ៉ាមីនជាប្អូនពៅ ឱ្យនៅជាមួយឪពុក។
បងៗបានទៅស្រុកអេស៊ីបពួកគេបានឈរនៅមុខនាយករដ្ឋមន្ត្រីស្រុកអេស៊ីប។
ពួកបងៗទាំងអស់នោះ គ្មានអ្នកណាមើលយ៉ូសែបស្គាល់ទេ។
ប៉ុន្តែ យ៉ូសែបវិញ គ្រាន់តែឃើញបងៗ គាត់ស្គាល់ភ្លាម។
យ៉ូសែប រីករាយជាខ្លាំងរហូតដល់យំ រួចនិយាយដោយសម្លេងក្អកក្អួលថា៖
«ពួកឯង ជាគិញដែលលួចចូលមកទីនេះដើម្បីស៊ើបការណ៍»។
ពួកបងៗក៏បាននិយាយថា៖ «អត់ទេ លោកម្ចាស់ ពួកខ្ញុំ គឺមកពីស្រុកកាណាន ហើយមកទីនេះដើម្បីទិញស្បៀងប៉ុណ្ណោះ»។





យ៉ូសែបក៏សួរម្ដងទៀតៈ «តើពួកអ្នក មានបងប្អូនទាំងអស់ប៉ុន្មាននាក់?»

«ទាំងអស់ ដប់ពីរនាក់ ប៉ុន្តែ ប្អូនពៅនៅផ្ទះ ហើយប្អូនម្នាក់ទៀតបានស្លាប់បាត់ហើយ»។

បងៗបានឆ្លើយទៅយ៉ូសែបដូច្នេះ។ យ៉ូសែបឮហើយ គាត់នឹករលឹកដល់បេនយ៉ាមីនជាខ្លាំង។

ដូច្នេះ យ៉ូសែបក៏បញ្ជារឱ្យទុកបងប្រុសម្នាក់ ហើយបងៗផ្សេងទៀត ត្រូវត្រឡប់ទៅវិញ ដើម្បីយកបេនយ៉ាមីនមក បើមិនយកមកទេ យ៉ូសែបនឹងសម្លាប់អ្នកដែលនៅទីនេះ។

ក្នុងចំណោមបងៗ យ៉ូសែបបានយកស៊ីម្មានទៅឃុំទុក ហើយបងៗប្រាំបួននាក់ទៀត ទទួលយកស្បៀងហើយក៏ ត្រឡប់ទៅកាណានវិញ។

មិនយូរប៉ុន្មាន បងៗរបស់យ៉ូសែបក៏បាននាំបេនយ៉ាមីនជាប្អូនពៅនោះមកអេស៊ីបម្ដងទៀត។

ពេលយ៉ូសែបបានឃើញបេនយ៉ាមីនភ្លាម គាត់សប្បាយចិត្តជាខ្លាំង។

ប៉ុន្តែ យ៉ូសែបសម្រេចចិត្តថានឹងធ្វើការល្បងលចិត្តបងៗរបស់គាត់។ ដូច្នេះ គាត់បានឱ្យគេយកពែងប្រាក់ដាក់ចូលក្នុង បាវរបស់បេនយ៉ាមីន។

ដើម្បីចោទប្រកាន់បេនយ៉ាមីនលួចពែងនោះ។ ហើយយ៉ូសែបក៏ចាប់បេនយ៉ាមីនទុក។

បងៗរបស់យ៉ូសែបទាំងអស់ បានលុតជង្គង់នៅមុខយ៉ូសែប។

យ៉ាកុបជាឪពុកពិបាកចិត្តព្រោះបាត់បងយ៉ូសែបម្នាក់ហើយ ដូច្នេះមិនអាចឱ្យបាត់បង់បេនយ៉ាមីនម្នាក់ទៀតបានទេ។

បងៗទាំងអស់បានឱបក្រាប់សុំអង្វរដល់យ៉ូសែប។

ពេលឃើញបងៗបង្ហាញក្ដីស្រឡាញ់ដល់បេនយ៉ាមីនជាប្អូនពៅដូច្នេះ ធ្វើឱ្យយ៉ូសែបបានយល់ច្បាស់ពីក្ដីស្រឡាញ់ របស់ឪពុក និងបងៗទាំងអស់។

ដោយទ្រាំទៀតលែងបាន យ៉ូសែបក៏បានរត់ទៅឱបបងៗរបស់គាត់ទាំងអស់ទាំងទ្រហោរយំព្រោះនឹករលឹកខ្លាំងពេក ហើយគាត់បានអត់ទោសដល់ពួកបងៗ។

ពួកបងៗមានការភ្ញាក់ផ្អើលជាខ្លាំង ព្រោះគិតថាយ៉ូសែបស្លាប់បាត់ហើយ ប៉ុន្តែ បែរជាជួបគ្នាម្ដងទៀតដូច្នេះ។

បងៗទាំងអស់មានការភិតភ័យជាខ្លាំងនៅចំពោះមុខយ៉ូសែបដែលបានក្លាយជានាយករដ្ឋមន្ត្រីអេស៊ីប ព្រោះកន្លងមក ពួកខ្លួនបានធ្វើអំពើមិនគប្បីដាក់យ៉ូសែប។

ប៉ុន្តែ យ៉ូសែប បានអត់ទោសដល់បងៗរបស់គាត់ដោយសុទ្ធចិត្ត ទាំងស្រក់ទឹកភ្នែក។

យ៉ូសែបដែលបានអត់ទោសឱ្យបងៗរបស់គាត់ បានរស់នៅយ៉ាងមានក្ដីសុខជាមួយនិងយ៉ាកុបជាឪពុក និងបងប្អូនទាំងអស់នៅក្នុងស្រុកអេស៊ីប។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។(លោកុប្បត្តិ ៥០:២០)

តែព្រះជាម្ចាស់បានធ្វើឱ្យការនោះប្រែទៅជាល្អ

**សកម្មភាពទី១**

យ៉ូសែបបានក្លាយជានាយករដ្ឋមន្ត្រីអេស៊ីប សូមផាត់ពណ៌មួកដែលនាយករដ្ឋមន្ត្រីអេស៊ីបពាក់ឱ្យបានស្អាត រួចកាត់វាចេញ ហើយបិទវានៅលើក្បាលរបស់យ៉ូសែប។ (សម្ភារៈ៖ ខ្មៅដៃពណ៌ កន្ត្រៃ កាវ)






រូបភាពរួចរាល់



**សកម្មភាពទី២** សូមគិតអំពីខ្លឹមសារមេរៀនដែលរៀនបាននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។

